# បោះឆ្នោតដោយសុវត្ថិភាពជាមួយ នឹង សន្លឹកឆ្នោតបោះតាមសំបុត្ររបស់អ្នក

អ្នកបោះឆ្នោតទាំងអស់នៅរដ្ឋ California នឹងទទួលសន្លឹកឆ្នោតបោះតាមសំបុត្រសម្រាប់ការបោះឆ្នោត នៅ **ថ្ងៃទី 3 ខែ វិច្ឆិកា ឆ្នាំ 2020**។ ការិយាល័យបោះឆ្នោតខោនធីរបស់អ្នក នឹងចាប់ផ្តើមផ្ញើរសន្លឹកឆ្នោតស្រដៀងនឹងរូបថតមួយ ខាង ក្រោមចាប់ពី **ថ្ងៃទី 5 ខែតុលា ឆ្នាំ 2020** តទៅ។




## ការបោះឆ្នោតតាមសំបុត្រគឺ ***<u>សុវត្ថិភាព</u>*** និង ***<u>ងាយស្រួល</u>***។

ក្រោយពេលគូសជម្រើសរបស់អ្នកនៅលើសន្លឹកឆ្នោតអ្នកគ្រាន់តែ៖

**បិទស្រោមសំបុត្រ។**
ដាក់សន្លឹកឆ្នោតរបស់អ្នក ទៅខាងក្នុងស្រោមសំបុត្រពីការិយាល័យបោះឆ្នោតខោនធីរបស់អ្នក។

**ចុះហត្ថលេខាលើវា។**
ត្រូវប្រាកដថា *<u>ហត្ថលេខានៅលើស្រោមសំបុត្រសន្លឹកឆ្នោតរបស់អ្នកត្រូវគ្នា</u>* ទៅនឹងហត្ថលេខា នៅលើប័ណ្ណបើកបរ California របស់អ្នក ឬ ប័ណ្ណអែឌីប្រចាំរដ្ឋរបស់អ្នកឬ ហត្ថលេខាដែលអ្នកបានផ្តល់ នៅពេលចុះឈ្មោះ។ ការិយាល័យបោះឆ្នោតប្រចាំខោនធីរបស់អ្នកនឹង ប្រៀបធៀបហត្ថលេខាទាំងនោះ ដើម្បីការពារ សន្លឹកឆ្នោតរបស់អ្នក។

**ផ្ញើរវាមកវិញ។**
<u>តាមសំបុត្រ</u>—សូមប្រាកដថាសន្លឹកឆ្នោតរបស់អ្នកត្រូវបានសម្គាល់ថាផ្ញើតាមប្រៃសណីយ៍ នៅត្រឹម **ថ្ងៃទី 3 ខែវិច្ឆិកា ឆ្នាំ 2020**។ មិនចាំបាច់បិទតែមទេ!

**ឬ**

<u>ដោយផ្ទាល់ខ្លួន</u>—ទម្លាក់សន្លឹកឆ្នោតរបស់អ្នកនៅប្រអប់ទម្លាក់សន្លឹកឆ្នោតដោយសុវត្ថិភាព ទីកន្លែង បោះឆ្នោត មជ្ឈមណ្ឌលបោះឆ្នោត ឬ ការិយាល័យបោះឆ្នោតប្រចាំខោនធីនៅត្រឹមម៉ោង **8:00 យប់ នៅថ្ងៃទី 3 ខែ វិច្ឆិកា ឆ្នាំ 2020**។

**តាមដានមើលវា។**
អ្នក អាច ចុះឈ្មោះ នៅតាម អាសយដ្ឋាន *wheresmyballot.sos.ca.gov* ឬ សុំការជូនដំណឹង តាមសារអក្សរ (SMS) អ៊ីម៉ែល ឬ ការហៅទូរសព្ទជាសំឡេង អំពីស្ថានភាព នៃសន្លឹកឆ្នោតបោះតាម សំបុត្ររបស់អ្នក។

**អ្នកបោះឆ្នោតដែលអាចបោះឆ្នោតតាមសំបុត្រ នឹងជួយធានាការរក្សាចម្ងាយរាងកាយដោយសុវត្ថិភាព នៅទីតាំងបោះឆ្នោត។**
ទីតាំងបោះឆ្នោតនឹងអាចប្រើប្រាស់បាន នៅក្នុងខោនធីទាំងអស់នៅមុនថ្ងៃបោះឆ្នោត។ ទីតាំងបោះឆ្នោតនឹងផ្តល់ជូនការចុះឈ្មោះអ្នកបោះឆ្នោត សន្លឹកឆ្នោតជំនួស ម៉ាស៊ីនបោះឆ្នោតសម្រាប់ជនពិការ និង ជំនួយផ្នែកភាសា។

# បោះឆ្នោតដោយសុវត្ថិភាពនៅទីតាំងបោះឆ្នោតមុនកំណត់ពេល

ទីតាំងបោះឆ្នោតមុនកំណត់ពេលមួយ ឬច្រើននឹងអាចប្រើប្រាស់បាន នៅក្នុងខោនធីជាច្រើន សម្រាប់ រយៈពេល **យ៉ាងតិចបួនថ្ងៃ** ចាប់ផ្តើមនៅថ្ងៃសៅរ៍ មុនការបោះឆ្នោត **ថ្ងៃទី 3 ខែវិច្ឆិកា ឆ្នាំ 2020**។ ទីតាំងបោះឆ្នោតនឹងផ្តល់ជូនការចុះឈ្មោះអ្នកបោះឆ្នោត សន្លឹកឆ្នោតជំនួស ម៉ាស៊ីនបោះឆ្នោត ជនពិការ និងជំនួយផ្នែកភាសា។

**អ្នកអាចជួយរក្សាទីតាំងបោះឆ្នោតឲ្យមានសុវត្ថិភាព** សម្រាប់អ្នកបោះឆ្នោតនិងបុគ្គលិកបោះឆ្នោត នៅក្នុងវិធីទាំងបីនេះ ៖

## រំលងបន្ទាត់។

អ្នកអាចប្រគល់សន្លឹកឆ្នោត ដែលបានបំពេញរួច **តាមសំបុត្រ** ដោយមិនចាំបាច់បោះត្រា នៅតាម **ប្រអប់ទម្លាក់សន្លឹកឆ្នោត**សុវត្ថិភាព ឬ នៅតាម **ទីតាំងបោះឆ្នោត**។ ទីតាំងបោះឆ្នោតនឹងមានបន្ទាត់ដាច់ដោយឡែក សម្រាប់អ្នកបោះឆ្នោតទម្លាក់សន្លឹកឆ្នោតដែលបាន បំពេញ រួច។

ស្វែងរកប្រអប់ទម្លាក់សន្លឹកឆ្នោតដែលនៅជិត សម្រាប់ទីតាំងបោះឆ្នោតនៅតាមអាសយដ្ឋាន *CAEarlyVoting.sos.ca.gov*

## បោះឆ្នោតមុនកំណត់ពេល។

ប្រសិនបើអ្នកទៅទីតាំងបោះឆ្នោតដោយផ្ទាល់ **សូមទៅមុនថ្ងៃបោះឆ្នោត** ដើម្បីជួយដល់ ការ រក្សាចម្ងាយរាងកាយ។ ទីតាំងបោះឆ្នោតមួយ ឬ ច្រើននៅក្នុងខោនធីជាច្រើន នឹង បើកសម្រាប់រយៈពេល **យ៉ាងតិចបួនថ្ងៃ** ចាប់ផ្តើមនៅថ្ងៃអាទិត្យមុនថ្ងៃបោះឆ្នោត។

## អនុវត្តតាមទម្រង់ការសុវត្ថិភាព។

ការពារសុខភាពរបស់អ្នកនិងសុខភាពរបស់អ្នកបោះឆ្នោតផ្សេងទៀត និងបុគ្គលិកបោះឆ្នោតនៅទីតាំង បោះឆ្នោតដោយការប្រុងប្រយ័ត្ន ដូចខាងក្រោម៖

## <u>បញ្ជីត្រួតពិនិត្យសុវត្ថិភាពទីតាំងបោះឆ្នោត</u>

- ☑ **ពាក់ម៉ាស** នៅពេលនៅទីតាំងបោះឆ្នោត។
- ☑ **រក្សាចម្ងាយប្រវែង 2 ដៃ** ពីអ្នកដទៃ។
- ☑ **លាងដៃ** មុននិងក្រោយចូលកន្លែងបោះឆ្នោត។
- ☑ **ប្រើប្រាស់ទឹកសម្លាប់មេរោគ** ក្រោយពេលប៉ះទ្វារ ឬឧបករណ៍បោះឆ្នោត។
- ☑ **យកប៊ិចមកតាមខ្លួន** ដើម្បីជៀសវាងការប៉ះផ្ទៃ ដែលមានការប៉ះពាល់ច្រើន។

***ចង់បានព័ត៌មានបន្ថែមអំពី របៀបរក្សាសុវត្ថិភាពនៅពេលបោះឆ្នោតឬ?***
អានគោលការណ៍ណែនាំរបស់មជ្ឈមណ្ឌល សម្រាប់ការគ្រប់គ្រង និងបង្ការជំងឺតាម
*www.cdc.gov/coronavirus/2019-ncov/community/election-polling-locations.html*

**អ្នកបោះឆ្នោតដែលអាចបោះឆ្នោតតាមសំបុត្រ នឹងជួយធានានូវការរក្សាចម្ងាយរាងកាយ សុវត្ថិភាព នៅ ទីតាំងបោះឆ្នោត។** ការិយាល័យបោះឆ្នោតប្រចាំខោនធីនឹងចាប់ផ្តើមបញ្ជូនសន្លឹកឆ្នោតបោះតាមសំបុត្រ ទៅអ្នកបោះឆ្នោតនៅរដ្ឋ California ចាប់ពី **ថ្ងៃទី 5 ខែតុលា ឆ្នាំ 2020** តទៅ។ សន្លឹកឆ្នោតផ្ញើរមកវិញតាមសំបុត្រ ត្រូវសម្គាល់ថាផ្ញើតាមប្រៃសណីយ៍ នៅត្រឹម **ថ្ងៃទី 3 ខែ វិច្ឆិកា ឆ្នាំ 2020**។ សន្លឹកឆ្នោតដែលប្រគល់មកតាមប្រអប់ទម្លាក់សន្លឹកឆ្នោតសុវត្ថិភាព ត្រូវផ្ញើមកត្រឹម **ម៉ោង 8:00 p.m. នៅថ្ងៃទី 3 ខែ វិច្ឆិកា ឆ្នាំ 2020**។